# ប្រាសាទបែបវលភីនៅក្នុងសិល្បៈឥណ្ឌានិងសិល្បៈខ្មែរ (ភាគ១)

ជាទូទៅគេដឹងថា ប្រាសាទជាកន្លែងសម្រាប់តម្កល់រូបគោរពនៃសាសនាផ្សេងៗ ពោលគឺប្រាសាទមានតួនាទីជាទីលំនៅរបស់អាទិទេព។[១] ប្រាសាទច្រើនមានលក្ខណៈជាសំណង់មានច្រើនជាន់(សង្កេតត្រង់ផ្នែកដំបូល) បង្ហាញពីឋានៈខ្ពង់ខ្ពស់នៃសំណង់ សាកសមជាទីកន្លែងនៃបុគ្គលដែលមានឋានៈខ្ពង់ខ្ពស់ដែរ។[២] សម្រាប់សង្គមខ្មែរ ប្រាសាទជាស្ថាបត្យកម្មមួយប្រភេទដែលកើតមានយ៉ាងហោចណាស់ក៏តាំងពីសម័យមុនអង្គរមក ម្ល៉េះ ហើយសំណង់ទាំងនោះ ច្រើនធ្វើឡើងដើម្បីឧទ្ទិសដល់ពុទ្ធសាសនា និងព្រាហ្មញ្ញសាសនា។

អត្ថបទនេះ ខ្ញុំនឹងលើកយកទម្រង់ស្ថាបត្យកម្មមួយប្រភេទគឺ "ប្រាសាទបែបវលភី" មកបង្ហាញ ដោយផ្តោតសំខាន់ទៅលើទម្រង់ទូទៅរបស់សំណង់ និងជាពិសេសផ្តោតលើការប្រៀបធៀបរវាងស្ថាបត្យកម្មខ្មែរជាមួយនឹងស្ថាបត្យកម្មឥណ្ឌា។ ដើម្បីងាយស្រួលក្នុងស្វែងយល់ពីទម្រង់ប្រាសាទបែបវលភីនៅក្នុងសិល្បៈខ្មែរ យើងគប្បីស្វែងយល់អំពីទម្រង់ប្រាសាទបែបវលភី នៅក្នុងសិល្បៈឥណ្ឌាជាមុនសិន។

នៅក្នុងសិល្បៈឥណ្ឌាគេសង្កេតឃើញថា ឥណ្ឌាមានប្រាសាទច្រើនទម្រង់និងសម្បូរបែបណាស់។ ការកំណត់លក្ខណៈរូបរាងរបស់ប្រាសាទទាំងនោះធ្វើឡើងដោយផ្អែកទៅលើលក្ខណៈដំបូលរបស់ប្រាសាទ។ នៅក្នុងសិល្បៈឥណ្ឌាមានទម្រង់ប្រាសាទ ៣ ប្រភេទ ដែលមានការនិយមខ្លាំងគឺ ប្រាសាទបែបនាគរ (Nāgara) ប្រាសាទបែបទ្រាវិឌ (Drāvīda) និងប្រាសាទបែបវេសរ (Vesara)។[៣] ដោយប្រាសាទបែបនាគរនិយមសាងនៅឥណ្ឌាភាគខាងជើង ប្រាសាទបែបទ្រាវិឌនិយមធ្វើនៅឥណ្ឌាភាគខាងត្បូង និងប្រាសាទបែបវេសរនិយមនៅឥណ្ឌាភាគកណ្តាល។ ក្រៅពីទម្រង់ប្រាសាទធំៗ ដែលបានពោលមកនេះ នៅមានទម្រង់ប្រាសាទផ្សេងទៀតដែលមាននៅក្នុងស្ថាបត្យកម្មឥណ្ឌា គ្រាន់តែមានការ

[១] Prasanna Kumar Archarya 1997: .397

[២] Chedha Tingsanchali 2022: 79-133.

[៣] Prasanna Kumar Archarya 1997: .397

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

និយមធ្វើតិចជាង ដូចជាប្រាសាទបែបផាម្សនា(Phāmsanā) ប្រាសាទបែបវលភី(Valabhī)) និងប្រាសាទបែបគជប្ឫស្ឋ (Gajapṛṣṭha)ជាដើម។[៤]

សម្រាប់ទម្រង់ប្រាសាទបែបវលភី (Valabhī) ជាប្រភេទប្រាសាទដែលមានធ្វើទាំងនៅក្នុងសិល្បៈឥណ្ឌាភាគខាងជើងនិងសិល្បៈឥណ្ឌាភាគខាងត្បូង។ វលភី ជាបច្ចេកទេសក្នុងស្ថាបត្យកម្មឥណ្ឌាខាងជើង តែនៅក្នុងស្ថាបត្យកម្មឥណ្ឌាខាងត្បូងគេហៅថាទម្រង់ប្រាសាទប្រភេទនេះថា សាលា (Śālā) ហើយនៅក្នុងស្ថាបត្យកម្មអូរិសសាហៅថា ខាខរាទេឧល (Khākharā Deul)។[៥] លក្ខណៈទូទៅនៃទម្រង់ប្រាសាទនេះរួមមាន ជាប្រាសាទទោលមានរាងចតុកោណកែង នៅចុងបញ្ចប់នៃកំពូលធ្វើជាដំបូលកោងវែងមានសណ្ឋានដូចដំបូលទូក។ លក្ខណៈនេះធ្វើឱ្យកើតមានហោជាងរាងក្រចកទំហំធំចំនួន២ នៅចុងសងខាងនៃដំបូល។ ចំណែកនៅតាមព្រំដំបូលនៃប្រាសាទលម្អដោយកូន**កលស** (Kalaśa) រៀងគ្នាជាជួរ[៦] ដែលក្នុងសិល្បៈខ្មែរហៅគ្រឿងលម្អស្ថាបត្យកម្មប្រភេទនេះថា**នាងប្រាល**[៧] **(រូបលេខ១)**។ ប្រាសាទបែបវលភីនៃឥណ្ឌាខាងជើងឃើញមាននៅក្នុងសិល្បៈបាលៈ (Pala) សិល្បៈអូរិសសា (Orissa) និងសិល្បៈប្រតិហារ(Pratihara)។ ចំណែកនៅឯឥណ្ឌាខាងត្បូងវិញ ប្រាសាទប្រភេទនេះឃើញមានធ្វើតាំងពីដើមសម័យបល្លវៈ(Pallava)រហូតដល់សម័យវិជ័យនគរ(Vijayanagara)។[៨]

ទោះបីជាទម្រង់ប្រាសាទបែបវលភីនៃសិល្បៈឥណ្ឌាខាងជើងមានលក្ខណៈទូទៅដូចគ្នានឹងទម្រង់ប្រាសាទបែបសាលានៃសិល្បៈឥណ្ឌាខាងត្បូងក៏ដោយ ក៏ទម្រង់នៃប្រាសាទទាំង២ភូមិភាគមានលក្ខណៈពិសេសរៀងៗខ្លួនដែរ។ លក្ខណៈសម្គាល់របស់ប្រាសាទបែបសាលាគឺ ដំបូលប្រាសាទអាចមានមួយជាន់ឬច្រើនជាន់ កើតចេញពីការចម្លងតួប្រាសាទផ្នែកខាងក្រោមដោយបង្រួមទំហំឱ្យតូចរួចយកទៅដាក់បន្ទុបពីខាងលើ

---

[៤] Chedha Tingsanchali 2022: 79-133.

[៥] ដដែល។

[៦] សូមអានបន្ថែមរឿងប្រាសាទបែបវលភីនៅ៖ Adam Hardy 2007: 108-110, 176-177។

[៧] ព្រាប ចាន់ម៉ារ៉ា ២០១២: ៦២។

[៨] Chedha Tingsanchali 2016: 55-59.

ត្រួតគ្នាជាថ្នាក់ៗ ប្រដេញទំហំគ្នាពីធំទៅតូចៗ នៅតាមជាន់នីមួយៗនៃដំបូលមានលម្អដោយកូនប្រាសាទរៀងគ្នាជាជួរតាមគ្រប់ជ្រុងទាំង៤ (រូបលេខ២)។ ថ្នាក់នៃដំបូលទាំងនេះខ្មែរយើងហៅថា រូត។[៩] ចំណែកឯប្រាសាទបែបវលភីវិញ ច្រើនធ្វើមួយជាន់ ដោយមានដំបូលខាងលើបង្អស់មានរាងកោងវែងដូចដំបូលទូក នៅអមសងខាងនៃដំបូលខាងលើនេះ តភ្ជាប់ដោយស្វាបដំបូលដែលមានរាងកោងដែរ (រូបលេខ៣)។

បើយើងសង្កេតពីសំណង់ប្រាសាទមួយចំនួនៅក្នុងសិល្បៈខ្មែរវិញយើងនឹងឃើញថាមានសំណង់ប្រាសាទទោលមួយចំនួនសាងឡើងក្នុងទម្រង់ចតុកោណកែង ដោយផ្នែកដំបូលមានលក្ខណៈកោងនិងមានសណ្ឋានដូចដំបូលទូក ដូចគ្នានឹងលក្ខណៈរបស់ប្រាសាទបែបវលភី ឬសាលានៅក្នុងសិល្បៈឥណ្ឌាដែរ ដូចជា ប្រភេទសំណង់ដែលមានរាងចតុកោណកែង និយមធ្វើបែបមុខទៅរកប្រាសាទកណ្តាល ដែលខ្មែរយើងនិយមហៅប្រាសាទទាំងនោះថា ហោត្រៃ ឬបណ្ណាល័យ ជាដើម (រូបលេខ៤)៕

## បញ្ជីឯកសារយោង

ព្រាប ចាន់ម៉ារ៉ា.

២០១២. *ពាក្យប្រើចំពោះសំណង់បុរាណនិងក្បាច់លម្អ*, ភ្នំពេញ។

Archarya, Prasanna Kumar

1997. *A Dictionary of Hindu Architecture*, New Delhi, Low Price Publication.

Hardy, Adam.

2007. *The Temple Architecture of India*, Chichester: Wiley.

Tingsanchali, Chedha.

2016. *Shikhara and Vimanan in Indian art and their influences to Southeast Asian*, Development Institute, Silpakorn University.

2022. *Temple in Southeast Asia*. Matichon, Bangkok.

---

[៩] ព្រាប ចាន់ម៉ារ៉ា ២០១២: ៦៨។

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

# បញ្ជីរូបភាព



រូបលេខ១៖ ប្រាសាទភីមរថ នៅទីក្រុង Mahabalipuram សិល្បៈបល្លវៈ ស.វ.ទី៧ (រូបថត៖ ឡេង ស៊ីវ៉ង)



រូបលេខ២៖ ប្រាសាទគណេសរថ នៅទីក្រុង Mahabalipuram សិល្បៈបល្លវៈ ស.វ.ទី៧ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបលេខ៣៖ ប្រាសាទ Vaitala Deula នៃរដ្ឋអូរិសសា, សិល្បៈអូរិសសា ស.វ.ទី៨

(រូបថត៖ https://sarsonkekhet.in/2019/09/24/odisha-style-bhubaneswar-vaital-deul-and-shishireshwara-temples/)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបលេខ២៤៖ បណ្ណាល័យខាងត្បូងនៃប្រាសាទបន្ទាយសំរែ, រចនាបថអង្គរ ស.វ.ទី១២ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់